00708590

E102

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 23 / 06 / 2011
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ ៖** ០០២/១៩-០៩-២០០៧-អវតក/អជសដ

**ភាគីដាក់ឯកសារ ៖** ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ

**ដាក់ជូន ៖** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម ៖** អង់គ្លេស

**កាលបរិច្ឆេទឯកសារ ៖** ២២ ខែ មិថុនា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ ៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់ ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន ៖

ឈ្មោះមន្ត្រីកត់ត្រា ៖

ហត្ថលេខា ៖

---

## សំណើជូនអង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការកំណត់កាលបរិច្ឆេទសវនាការនាពេលអនាគត

---

**ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ៖**

មេធាវី Diana ELLIS, QC

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ៖**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU FORT

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ មណី

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា ៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

E102

## I. សេចក្តីផ្តើម

១. ក្រុមមេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងសូមមេត្តាពិគ្រោះយោបល់ជាមួយនឹងមេធាវីការពារក្តីជាតិ និងអន្តរជាតិមុននឹងកំណត់កាលបរិច្ឆេទបើកសវនាការជំនុំជម្រះសំណុំរឿង ០០២ ដែលនឹងគ្រោងធ្វើនាពេលអនាគត។

## II. សាវតារ

២. កាលបរិច្ឆេទសម្រាប់បើកសវនាការបឋម នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ទើបតែកំណត់នៅប៉ុន្មានសប្តាហ៍មុននេះប៉ុណ្ណោះ។ ការកំណត់កាលបរិច្ឆេទនេះត្រូវបានធ្វើឡើងដោយមិនបានពិគ្រោះយោបល់ជាមួយនឹងមេធាវីការពារក្តីជនជាប់ចោទទាំងបួនរូបនោះទេ។ អាស្រ័យហេតុនេះហើយទើបសហមេធាវីអន្តរជាតិការពារក្តីលោកស្រី អៀង ធីរិទ្ធ មិនអាចចូលរួមក្នុងសវនាការបឋមនេះឡើយ ដោយសារមានការងារផ្សេងត្រូវបំពេញមិនអាចខានបាន។

៣. បន្ទាប់ពីសហមេធាវីការពារក្តីអន្តរជាតិបានទទួលព័ត៌មានពីអង្គជំនុំជម្រះសាលាដំបូងអំពីការកំណត់កាលបរិច្ឆេទបើកសវនាការបឋម នៅថ្ងៃទី ២៧ ខែ មិថុនាភ្លាម សហមេធាវីការពារក្តីបានធ្វើសំណើទៅអង្គជំនុំជម្រះសាលាដំបូងតាមរយៈលោកស្រី Susan Lamb ដើម្បីស្នើសុំថាតើអាចផ្លាប់ប្តូរកាលបរិច្ឆេទកំណត់នេះដែរឬទេ ប្រសិនបើមានការឯកភាពពីភាគទាំងអស់នោះ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កាលបរិច្ឆេទនេះនឹងមិនផ្លាស់ប្តូរឡើយ។

៤. សហមេធាវីអន្តរជាតិការពារក្តីលោកស្រី អៀង ធីរិទ្ធ សូមឲ្យអង្គជំនុំជម្រះសាលាដំបូងយកចិត្តទុកដាក់លើបញ្ហានេះដើម្បីកុំឲ្យបញ្ហាដដែលនេះកើតមានទៀតនាពេលអនាគត។ យើងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អាចមានសវនាការផ្សេងទៀតដែលនឹងត្រូវរៀបចំធ្វើឡើង មុនពេលសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានបើកសំណុំរឿងនេះជាផ្លូវការ និងចាប់ផ្តើមបង្ហាញភស្តុតាង ។

## III. ច្បាប់

៥. គោលការណ៍រួមដែលពាក់ព័ន្ធមានចែងក្នុងវិធាន ២១នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលចែង*ក្នុងចំណុចពាក់ព័ន្ធ* ៖

E102

១. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និង បទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី ប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមាន ចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ ៖
[...]
ឃ) [...] ជនទាំងនេះមានសិទ្ធិទទួល [...] ការពារក្ដីតាមការជ្រើសរើសរបស់ខ្លួន [...]។

៦. ជនជាប់ចោទអាចទទួលបានសិទ្ធិនេះពេញលេញ តែនៅពេលអង្គជំនុំជម្រះសាលាដំបូងធ្វើការ ពិចារណានៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនេះថា មេធាវីការពារក្ដីជនជាប់ចោទមាន ធុរៈផ្នែកវិជ្ជាជីវៈ និងផ្ទាល់ខ្លួន ដែលធ្វើឲ្យមេធាវីការពារក្ដីមិនអាចចូលរួមក្នុងសវនាការនៅពេល គ្មានការពិគ្រោះយោបល់អំពីកាលបរិច្ឆេទដែលបានកំណត់កន្លងមក។

៧. ក្នុងករណីនេះ សហមេធាវីការពារក្ដីលោកស្រី អៀង ធីរិទ្ធ សូមស្នើដោយគោរពដល់អង្គជំនុំ ជម្រះសាលាដំបូងសូមមេត្តាធ្វើការពិគ្រោះយោបល់ជាមួយនឹងមេធាវីការពារក្ដីជាតិ និង អន្តរជាតិមុននឹងកំណត់កាលបរិច្ឆេទបើកសវនាការនាពេលអនាគតដើម្បីកុំឲ្យបញ្ហានេះកើត មានម្ដងទៀត។ ដោយអនុលោមតាមគោលការណ៍នៃការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និង យោងតាមវិធាន ២១ ១(ឃ)នៃវិធានផ្ទៃក្នុង ការពិគ្រោះយោបល់នេះនឹងធានាថា សិទ្ធិរបស់ លោកស្រី អៀង ធីរិទ្ធ ក្នុងការមានតំណាងតាមការជ្រើសរើសរបស់ខ្លួនមិនត្រូវបានបដិសេធ ដោយសារតែអវត្តមានសហមេធាវីអន្តរជាតិការពារក្ដីលោកស្រីក្នុងពេលសវនាការឡើយ។

៨. សហមេធាវីការពារក្ដីអន្តរជាតិគ្មានបំណងមិនគោរពអង្គជំនុំជម្រះសាលាដំបូង ដោយសារការ មិនអាចចូលរួមក្នុងសវនាការបឋមនេះឡើយ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីអន្តរជាតិការពារក្ដី អៀង ធីរិទ្ធ | ២២ មិថុនា ឆ្នាំ ២០១១ | មេធាវី Diana ELLIS, QC | ភ្នំពេញ | |

Original EN: 00707855-00707857